**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ០០៤ ប្រក...... អវអរ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជោគជ័យនៃដំណើរបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសិង្ហបុរី របស់ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាល អញ្ជើញធ្វើមាតុភូមិនិវត្តន៍ មកដល់រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ នេះ បន្ទាប់ពីបានបំពេញទស្សនកិច្ចផ្លូវការ ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ នៅសាធារណរដ្ឋសិង្ហបុរី តបតាមការអញ្ជើញរបស់ **សមភាគីសិង្ហបុរី**។ ដំណើរបំពេញទស្សនកិច្ចផ្លូវការរយៈពេល ២ថ្ងៃនេះ បានទទួលលទ្ធផលផ្លែផ្កាយ៉ាងច្រើន ទាំងផ្នែកនយោបាយការទូត សេដ្ឋកិច្ច និងពាណិជ្ជកម្ម ដោយកម្ពុជា និងសិង្ហបុរីបានឯកភាពក្នុងការជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ និងប្រកបដោយវិបុលភាព។

**ក្នុងក្របខណ្ឌនយោបាយ និងការទូត៖ សម្តេចធិបតី** បានអញ្ជើញជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម ថាមែន សាន់មូហ្គារ៉ាត់ណាម ប្រធានាធិបតី នៃសាធារណរដ្ឋសិង្ហបុរី** នៅមុនជំនួបទ្វេភាគីជាមួយ **ឯកឧត្តម ឡរ៉េន វ៉ុង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី** និង **ឯកឧត្តម លី សៀនលុង ទេសរដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី**។

**ជំនួបសម្តែងការគួរសមជាមួយ ឯកឧត្តម ថាមែន សាន់មូហ្គារ៉ាត់ណាម ប្រធានាធិបតី នៃសាធារណរដ្ឋសិង្ហបុរី៖ ឯកឧត្តមប្រធានាធិបតី** បានវាយតម្លៃខ្ពស់លើទំនាក់ទំនងដ៏ល្អរវាងសិង្ហបុរី-កម្ពុជាលើគ្រប់វិស័យរួមមាន៖ សេដ្ឋកិច្ច ពាណិជ្ជកម្ម ការពារជាតិ បណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្ស។ ទន្ទឹមគ្នានេះ **ឯកឧត្តមប្រធានាធិបតី** បានបង្ហាញសុទិដ្ឋិនិយមថា សក្តានុពលនៃធនធានមនុស្សវ័យក្មេង និងវឌ្ឍនភាព នៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនៅកម្ពុជា នឹងក្លាយជាកម្លាំងចលករក្នុងការទាក់ទាញការវិនិយោគ និងជំរុញការអភិវឌ្ឍ ជាពិសេសវិស័យថាមពល ឧស្សាហកម្ម កម្មន្តសាល និងវិស័យសក្តានុពលផ្សេងៗទៀត។



ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៤១ មហាវិថីសហពន្ធរុស្ស៊ី (១១០), រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website : rgsu.gov.kh / Facebook page : Royal Government Spokesperson Unit / Telegram : https : // t. me / Cambodia Government Spokesperson

ជាការឆ្លើយតប **សម្តេចធិបតី** បានគូសបញ្ជាក់ថា ប្រទេសទាំងពីរនឹងស្វែងរកកិច្ចសហប្រតិបត្តិការស្តីពីការអភិវឌ្ឍគ្រប់ទំនាក់ទំនង ដូចជា ទំនាក់ទំនងធុរកិច្ច វិស័យឯកជននិងឯកជន រដ្ឋាភិបាលនិងរដ្ឋាភិបាល និងទំនាក់ទំនងក្នុងទិដ្ឋភាពផ្សេងទៀត។

**សម្តេចធិបតី** និង **ឯកឧត្តមប្រធានាធិបតី** ក៏បានពិភាក្សាអំពីយន្តការនិងក្របខណ្ឌគោលនយោបាយនានាសម្រាប់កិច្ចការពារបរិស្ថាន ជាពិសេសការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាបាននូវភាពធន់របស់សេដ្ឋកិច្ចនៃប្រទេសទាំងពីរ ដោយផ្តោតលើការពង្រីកការប្រើប្រាស់ថាមពលកកើតឡើងវិញ ដែលអាចឈានដល់ការសម្រេចបាននូវបណ្តាញអគ្គិសនីអាស៊ាន (ASEAN Power Grid)។ បន្ថែមពីនេះ **សម្តេចធិបតី** និង **ឯកឧត្តមប្រធានាធិបតី** មានសុទិដ្ឋិនិយមថា ភាគីទាំងពីរនឹងបន្តធ្វើឱ្យកាន់តែល្អប្រសើរថែមទៀតនូវទំនាក់ទំនងដែលជាកត្តាកំណត់សម្រាប់កិច្ចសហប្រតិបត្តិការ ដើម្បីទទួលបាននូវវិបុលភាពនាពេលអនាគត។

**ជំនួបសម្តែងការគួរសមជាមួយ ឯកឧត្តម ឡរ៉េន វ៉ុង នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី៖ សម្តេចធិបតី** ត្រូវបានទទួលបដិសណ្ឋារកិច្ចប្រកបដោយកិត្តិយស នៅវិមានរដ្ឋាភិបាល Istana នៃប្រទេសសិង្ហបុរី។ ក្នុងឱកាសនៃជំនួបទ្វេភាគីនេះ ថ្នាក់ដឹកនាំទាំងពីរ បានសម្តែងការពេញចិត្តចំពោះការរីកចម្រើនយ៉ាងខ្លាំងនៃទំនាក់ទំនងរវាងប្រទេសទាំងពីរលើគ្រប់វិស័យ តាមរយៈការផ្លាស់ប្តូរទស្សនៈរួមគ្នាអំពីមធ្យោបាយនានាក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅ និងពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ខណៈដែលប្រទេសទាំងពីរគ្រោងនឹងប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតដ៏យូរអង្វែងនៅឆ្នាំ២០២៥ខាងមុខ។ តាមរយៈជំនួបទ្វេភាគីនាពេលនេះ ភាគីទាំងពីរមានជំនឿទុកចិត្តយ៉ាងមុតមាំ លើភាពជាដៃគូទ្វេភាគី និងឯកភាពគ្នាក្នុងការបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរួម ដោយបានបញ្ជាក់ពីការគាំទ្រ និងចែករំលែកនូវបទពិសោធគ្នាទៅវិញទៅមកលើវិស័យសំខាន់ៗ រួមមាន៖ (១) កិច្ចសហប្រតិបត្តិការលើវិស័យនយោបាយ ដោយបន្តកិច្ចពិគ្រោះយោបល់នយោបាយជាទៀងទាត់រវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ដើម្បីពង្រីកនូវកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ក្រោយពីបានខកខានតាំងពីឆ្នាំ២០១៩ (២) កិច្ចសហប្រតិបត្តិការជំរុញវិស័យពាណិជ្ជកម្ម និងការវិនិយោគ ដោយរៀបចំក្រុមការងាររួមដើម្បីពិភាក្សាអំពីមធ្យោបាយ និងផែនការសកម្មភាពឱ្យកាន់តែប្រសើរឡើង (៣) ការបន្តកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរប្រជាជននិងប្រជាជន ដែលរួមមានការកសាងនូវមូលធនមនុស្ស ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជំរុញវិស័យទេសចរណ៍ តាមរយៈការពង្រីកជើងហោះហើរផ្ទាល់ពីសិង្ហបុរី-ខេត្តព្រះសីហនុ បន្ថែមលើជើងហោះហើរដែលមានស្រាប់ (៤) កិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខថាមពល៖ ភាគីទាំងពីរបានអបអរសាទរចំពោះលទ្ធផល នៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីរវាងប្រទេសកម្ពុជា-ឡាវ-សិង្ហបុរី ការបង្កើតក្រុមការងារថ្នាក់រដ្ឋមន្ត្រីនៃប្រទេសទាំងបី និងលើកទឹកចិត្តឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធបន្ថែមទៀត និង (៥) កិច្ចសហប្រតិបត្តិការលើ វិស័យការពារជាតិ និងសន្តិសុខ៖ ភាគីទាំងពីរបានពិភាក្សាអំពីការផ្លាស់ប្តូរទស្សនកិច្ចនៃមន្ត្រីជាន់ខ្ពស់ និងវគ្គបណ្តុះបណ្តាល ព្រមទាំងបានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការលើការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ភេរវកម្ម ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន បទល្មើសបច្ចេកវិទ្យា និងការឆបោកតាមប្រព័ន្ធអនឡាញ។ ភាគីទាំងពីរ ក៏បានឯកភាពគ្នាលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនៃ

រដ្ឋាភិបាលទាំងពីរក្នុងការបន្តកិច្ចពិភាក្សាគ្នា ដើម្បីកំណត់ឱ្យបានជាក់លាក់អំពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម ពាណិជ្ជកម្ម វិនិយោគ និងវិស័យផ្សេងៗទៀត។

បន្ថែមពីលើនេះ ភាគីទាំងពីរបានបន្តពិភាក្សាគ្នាអំពីបញ្ហាក្នុងតំបន់ និងអន្តរជាតិមួយចំនួន ដើម្បីចូលរួមក្នុងការកសាងសន្តិភាព ស្ថិរភាព សាមគ្គីភាព និងវិបុលភាពនៅក្នុងតំបន់ និងពិភពលោក ក៏ដូចជាផ្តល់អត្ថប្រយោជន៍រួមរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរ ក៏បានឯកភាពក្នុងការបន្តកិច្ចសហប្រតិបត្តិការលើវិស័យធនាគារ និងហិរញ្ញវត្ថុ និងវិស័យឌីជីថល ព្រមទាំងបានចូលរួមជាអធិបតី ក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវគម្រោងច្រកច្រករបៀងតម្លាភាពហិរញ្ញវត្ថុ (Financial Transparency Corridor) និងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការនៃរដ្ឋាភិបាលឌីជីថល។

**ជំនួបសម្តែងការគួរសមជាមួយ ឯកឧត្តម លី ស៊ៀនលុង ទេសរដ្ឋមន្ត្រី នៃសាធារណរដ្ឋសិង្ហបុរី៖ ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលប្រកបដោយផ្លែផ្កា នៃកិច្ចប្រជុំពិភាក្សាការងាររបស់ **សម្តេចធិបតី** ជាមួយ **ឯកឧត្តមប្រធានាធិបតី** និង **ឯកឧត្តមនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៤។ ក្នុងឱកាសនៃជំនួបដ៏វិសេសនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានក្រាបបង្គំទូលថ្វាយព្រះពរ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងឱកាសនៃព្រះរាជពិធីចម្រើនព្រះជន្មាយុ គម្រប់៨៨ យាងចូល ៨៩ព្រះវស្សា និងបានផ្តាំផ្ញើការសួរសុខទុក្ខជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** ជាពិសេស**ឯកឧត្តម**សង្ឃឹមថា នឹងរង់ចាំទទួលបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅចំពោះដំណើរបំពេញទស្សនកិច្ចរបស់ **សម្តេចតេជោ** នៅសិង្ហបុរី នាពេលខាងមុខ។

ជាការឆ្លើយតប **សម្តេចធិបតី** បានបញ្ជាក់ថា ប្រទេសសិង្ហបុរីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា នាពេលកន្លងមក។ **សម្តេចធិបតី** និង **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសរំលេចផងដែរថា កម្ពុជា និងសិង្ហបុរី មានសក្តានុពលក្នុងការពង្រីកកិច្ចសហប្រតិបត្តិការជាច្រើនបន្ថែមទៀត សម្រាប់ជាឧត្តមប្រយោជន៍នៃប្រទេសទាំងពីរ ដោយផ្តោតលើវិស័យសំខាន់ៗមួយចំនួន ដូចជា៖ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការអប់រំ សន្តិសុខថាមពល ការការពារបរិស្ថាន ការថែរក្សាសុខសន្តិភាពនៅក្នុងតំបន់ និងការធានាបាននូវវិបុលភាពក្នុងតំបន់។

**ក្នុងក្របខណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ៖ សម្តេចធិបតី** បានអញ្ជើញចូលរួមជាអធិបតីក្នុងវេទិកាធុរកិច្ចកម្ពុជា-សិង្ហបុរី ដោយមានវិនិយោគិនចូលរួមទាំងកម្ពុជានិងសិង្ហបុរីចំនួន ៤៨១នាក់ តំណាងក្រុមហ៊ុនចំនួន ៣៤៨ក្រុមហ៊ុន។ នៅក្នុងវេទិកានេះ **សម្តេចធិបតី** បានបង្ហាញពីសក្តានុពលវិនិយោគនៅកម្ពុជា ក៏ដូចជាយន្តការលើកទឹកចិត្តដល់វិនិយោគិន រួមទាំងច្បាប់នៃការវិនិយោគផង ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមអំពីកម្ពុជាដល់វិនិយោគិនគ្រប់រូប។ **សម្តេចធិបតី** លើកទឹកចិត្តឱ្យមានការសិក្សាឈ្វេងយល់បន្ថែមអំពីឱកាសវិនិយោគលើវិស័យសក្តានុពលដែលទីផ្សារកម្ពុជាកំពុងត្រូវការ ជាពិសេសកម្ពុជាមានកម្លាំងពលកម្មយុវជនវ័យក្មេងដែលពោរពេញដោយសក្តានុពល និងចំណេះដឹង រហូតដល់ ៦៥% នៃប្រជាជនសរុប។

**សម្ដេចធិបតី** ចាត់ទុកវេទិកាធុរកិច្ចកម្ពុជា-សិង្ហបុរីនេះ ថាបានដើរតួនាទីដ៏សំខាន់ក្នុងការធ្វើឱ្យទំនាក់ទំនងសហគមន៍ធុរកិច្ចរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅ និងបង្កើតកាលានុវត្តភាពដែលផ្ដល់ប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីកសាងទំនាក់ទំនងសេដ្ឋកិច្ចរឹងមាំ និងបង្កើតអនាគតប្រកបដោយវិបុលភាពសម្រាប់ប្រជាជាតិទាំងពីរ។ សិង្ហបុរីតែងតែស្ថិតក្នុងចំណោមប្រភពវិនិយោគបរទេសកំពូលទាំង១០ នៅកម្ពុជា ក្នុងទសវត្សរ៍កន្លងមក ដោយបានចូលរួមចំណែកជិត ២ពាន់លានដុល្លារអាម៉េរិក ក្នុងទិដ្ឋភាពវិនិយោគរបស់កម្ពុជា ដែលរួមមាន វិស័យកម្មន្តសាល អចលនទ្រព្យ និងបដិសណ្ឋារកិច្ច ខណៈដែលក្រុមហ៊ុនយីហោល្បីៗរបស់សិង្ហបុរី ក៏បានបង្ហាញវត្តមានដ៏រឹងមាំនៅកម្ពុជា ដែលឆ្លុះបញ្ចាំងពីភាពជោគជ័យនិងសក្ដានុពលនៃការវិនិយោគនៅកម្ពុជា។

ក្នុងអំឡុងនៃវេទិកាធុរកិច្ចកម្ពុជា-សិង្ហបុរីនេះ **សម្ដេចធិបតី** ក៏បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងពិធីផ្លាស់ប្ដូរអនុស្សរណៈនៃការយោគយល់គ្នាលើឯកសារចំនួន ៣ រួមមាន៖ (១) អនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសហព័ន្ធធុរកិច្ចសិង្ហបុរី (២) ការចុះហត្ថលេខាសាក្សីភាពស្ដីពី "ការចាប់ផ្ដើមគម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជា និងគ្រឹះស្ថានហិរញ្ញវត្ថុសិង្ហបុរី" និង (៣) អនុស្សរណៈនៃការយោគយល់គ្នា រវាងវិទ្យាស្ថានបណ្ដុះបណ្ដាលខ្សែច្រវាក់ផ្គត់ផ្គង់ និងភស្តុភារកម្មសិង្ហបុរី និងក្រុមហ៊ុន PPLC Superport & Industrial Co., Ltd. របស់កម្ពុជា។

នៅក្នុងឱកាសដំណើរទស្សនកិច្ចផ្លូវការរបស់ **សម្ដេចធិបតី** នៅសាធារណរដ្ឋសិង្ហបុរីនេះដែរ **សម្ដេច** ក៏បានអញ្ជើញទៅទស្សនកិច្ចនៅវិទ្យាស្ថានពហុបច្ចេកទេសណានយ៉ាង និងមជ្ឈមណ្ឌលនវានុវត្តន៍សម្រាប់ឧបករណ៍អេឡិចត្រូនិក និងអ៊ីនធឺណិត រួមទាំងអគារហេដ្ឋារចនាសម្ព័ន្ធរបស់ក្រុមហ៊ុនកាភែល (Kappel)។

សូមបញ្ជាក់ថា នេះជាដំណើរទស្សនកិច្ចក្រៅប្រទេស **លើកទី១៥** និងជា**លើកទី៥** ក្នុងតំបន់អាស៊ាន របស់ **សម្ដេចធិបតី ហ៊ុន ម៉ាណែត** ក្នុងនាមជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបំពេញបេសកកម្មការទូតដ៏សកម្មក្លៀវក្លា ដោយបាននាំមកនូវសមិទ្ធផលថ្មីៗជាច្រើន ទាំងផ្នែកការទូតនិងសេដ្ឋកិច្ច ជាឧត្តមប្រយោជន៍ជូនជាតិមាតុភូមិនិងប្រជាពលរដ្ឋ ជាពិសេសគឺដើម្បីលើកស្ទួយកិត្យានុភាពជាតិកម្ពុជានៅលើឆាកអន្តរជាតិ។

ថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤